# សត្វមានសំបកមានសុខភាព និងជំរើសអំពីម្ហូបសមុទ្រ

សត្វមានសំបកអាចទិញបានដោយសុវត្ថិភាពពីស្ទើរគ្រប់ហាងលក់ទំនិញ និងភោជនីយ ដ្ឋាន ។ ជនណាដែលលក់សត្វមានសំបក រួមទាំងហាងលក់ទំនិញ ភោជនីយដ្ឋាន និង តាមរថយន្តត្រក់ ត្រូវតែមានអាជ្ញាប័ណ្ណពីទីក្រុង និងពីរដ្ឋ ។ ការនេះគឺដើម្បីធានាថា សត្វមានសំបកគឺស្អាត ហើយមានសុវត្ថិភាពសំរាប់បរិភោគ ។

ត្រូវមានការប្រុងប្រយ័ត្នជាពិសេសអំពីការទិញម្ហូបពីរថយន្តត្រក់ - ត្រូវពិនិត្យមើលឲ្យច្បាស់ថាគេមានអាជ្ញាប័ណ្ណ ។ សត្វមានសំបកដែលបានលក់ដោយគ្មានអាជ្ញាប័ណ្ណប្រហែលគ្មាន សុវត្ថិភាពសំរាប់បរិភោគឡើយ ។ ត្រូវលាងឲ្យស្អាត និងចំអិនឲ្យឆ្អិនល្អមុននឹងបរិភោគសត្វមានសំបក ។

អ្នកមិនចាំបាច់មានអាជ្ញាប័ណ្ណទេសំរាប់ការស្ទូចត្រីកំសាន្តនៅក្នុងតំបន់ Boston Harbor ។ ត្រី Stiped bass (កំរិតឲ្យយក **2** ក្នុងមួយថ្ងៃ) និងត្រីដីទៃផ្សេងទៀតអាចចាប់ពីឆ្នេរសមុទ្របាន ។

The Boston Harbor Association

*for a clean, alive and accessible Boston Harbor*

*www.tbha.org 617-482-1722*




MASSACHUSETTS ENVIRONMENTAL TRUST

គំនូរអំពីសត្វមានសំបកជាការផ្សាយរបស់ New England Aquarium [ជលវប្បដ្ឋាន New England] (NEAq) ។ គំនូរនេះអាចចំឡងបានសំរាប់ការអប់រំ មិនមែនប្រើសំរាប់លក់ សូមរួមបញ្ចូលនូវសេចក្តីស្រង់សំណៅដើមរបស់ NEAq ផង ។

សមាគម Boston Harbor Association សំរាប់ការសំអាត រស់រវើក និងលទ្ធភាពចេញចូលតំបន់ Boston Harbor 617-482-1722

# តំបន់ **Boston Harbor** សត្វមានសំបក ការប្រយ័ត្នផ្នែកសុខភាព

**គ្មានការចាប់យកសត្វមានសំបក**

កំណរក្រខ្វក់នៅតំបន់ Boston Harbor ធ្វើមិនឲ្យមានសុវត្ថិភាពក្នុងការបរិភោគសត្វមានសំបក ដោយរួមទាំង លៀសសំបករឹង លៀសសំបកទន់ razor clams ខ្យង លៀស សមុទ្រ ងាវសមុទ្រ គ្រំ និងសត្វមានសំបកសណ្ឋានតូចៗ (ខ្មៅ) ។ ដោយមូលហេតុនេះ ជាការខុសច្បាប់ក្នុងការចាប់សត្វមានសំបកដោយផ្ទាល់ពីតំបន់ Boston Harbor ។

# ការចាប់អារម្មណ៍អំពីសុខភាព

សត្វមានសំបកនៅក្នុងតំបន់ Boston Harbor អាចមានកំណរក្រខ្វក់ជាមួយបាក់តេរី វីរុស និងជាតិគីមី ។ រោគសញ្ញាពីការបរិភោគសត្វមានសំបកដែលមានកំណរក្រខ្វក់ មានរួមដូចជាក្អួត ចង្អោរ រាគរូស ឈឺពោះ ត្រជាក់រងារ និងគ្រុន ។ ជំងឺរលាកថ្លើមជំពូក A (ជំងឺថ្លើម) និងជំងឺធ្ងន់ធ្ងរដទៃៗទៀតក៏អាចបណ្តាលមកពីការបរិភោគសត្វសំបកដែលមានកំណរក្រខ្វក់ដែរ ។



សត្វមានសំបកតូចៗ (ខ្ចៅ)

បណ្តាជនខាងក្រោមនេះជាក្រុមងាយរងគ្រោះជាពិសេសចំពោះជំងឺមកពីការបរិភោគសត្វមានសំបកដែលមានកំណរក្រខ្វក់:

- ក្មេង
- ស្ត្រីមានផ្ទៃពោះ និងស្ត្រីបំបៅកូនដោយទឹកដោះ
- មនុស្សចាស់
- ជនដែលមានប្រព័ន្ធស៊ាំក្នុងខ្លួនខ្សោយ



លៀសសំបករឹង

ពីព្រោះសត្វមានសំបកដែលមានកំណរក្រខ្វក់មិនមានអ្វីខុសប្លែកគ្នាពីសត្វមានសំបកដែល មានសុខភាពល្អទេ ដោយគ្រាន់តែមើលឃើញសត្វមានសំបកនេះ គេមិនអាចកំណត់ថាវា នឹងមានសុវត្ថិភាពសំរាប់បរិភោគឬយ៉ាងណាទេ ។ ការចំអិនសត្វមានសំបកនេះឲ្យឆ្អិនត្រឹម ត្រូវអាចបន្ថយគ្រោះថ្នាក់នៃជំងឺខ្លះៗ ប៉ុន្តែគេមិនអាចធានាថាសត្វមានសំបកដែលយកបាន ពី Boston Harbor សុទ្ធតែមានសុវត្ថិភាពសំរាប់បរិភោគទាំងអស់ទេ ។ ទូរស័ព្ទមកវេជ្ជ បណ្ឌិតណាម្នាក់ បើសិនជាអ្នកមានជំនឿថាអ្នកប្រហែលបានបរិភោគសត្វមានសំបកដែល មានកំណរក្រខ្វក់ ។



គ្រំខៀវ

# បំរាមចាប់សត្វមានសំបកនៅ Boston Harbor

ការចាប់សត្វមានសំបកសំរាប់កំសាន្តគឺមិនអនុញ្ញាតនៅក្នុង Boston Harbor ទេ ។ ការចាប់សត្វមានសំបកមិនអនុញ្ញាតនៅក្នុង Boston (រួមទាំង Boston ខាងកើត Downtown, Boston ខាងត្បូង និង Dorchester) និងទីក្រុងជុំវិញរួមទាំង Lynn, Revere, Winthrop, Chelsea, Quincy, Weymouth, Hingham និង Hull. ការផាកពិន័យចំពោះការល្មើសមានកំរិតពី $300 ដល់ $2,000 និងមានរួមនូវការជាប់ពន្ធនាគារបីឆ្នាំទៀតផង ។

ការចាប់លៀសសំបកទន់សំរាប់ពាណិជ្ជកម្មគឺត្រូវបានអនុញ្ញាតឲ្យយកនៅតាមតំបន់ខ្លះនៅ Boston Harbor - ប៉ុន្តែទាល់តែមានអាជ្ញាប័ណ្ណពីរដ្ឋ និងពីក្រុងប្រចាំតំបន់តែប៉ុណ្ណោះ ។ លៀសទាំងនោះត្រូវបានគេសំអាតកំណរក្រខ្វក់ចេញមុននឹងត្រូវបានលក់ទៅឲ្យសាធារណៈ ។ សំរាប់ពត៌មានអំពីអាជ្ញាប័ណ្ណពាណិជ្ជកម្មសត្វមានសំបក សូមទាក់ទងមកនាយកដ្ឋាន Massachusetts Division of Marine Fisheries [នាយកដ្ឋាន ផ្នែកអាជីវកម្មសត្វសមុទ្រនៃរដ្ឋ Massachusetts] តាមទូរស័ព្ទលេខ 617-626-1520។



លៀសសំបកទន់